01303896

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 07 / 2016
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E419/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកជាភស្តុតាងនូវរបាយការណ៍របស់អង្គភាពគាំពារជនរងគ្រោះអំពីពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណើមួយ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានផ្ញើជូនសំណៅជាការជូនដំណឹងនៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ ហើយក្រោយមក មេធាវីការពារក្តី នួន ជា ក៏បានដាក់សំណើនេះនៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦ ("សំណើ" ឯកសារ E419) សុំឱ្យទទួលយកជាឯកសារភស្តុតាងនូវរបាយការណ៍ដែលរៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះ ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈុន សាម៉ន (2-TCCP-236) ("របាយការណ៍" ឯកសារ D22/2479/1)។ នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើ ដែលសំណៅនៃចម្លើយតបនោះត្រូវបានផ្ញើជាការជូនដំណឹងទៅភាគី

ទាំងអស់ កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ ដោយជំទាស់ទៅនឹងការទទួលយករបាយ-ការណ៍នោះជាឯកសារភ័ស្តុតាង (ឯកសារ E419/1)។ នៅក្នុងអំឡុងពេលសវនាការថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ មុនការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236 អង្គ-ជំនុំជម្រះសាលាដំបូងបានទទួលយករបាយការណ៍នេះជាឯកសារភ័ស្តុតាង ដោយសំអាងហេតុនឹងចេញតាមក្រោយ (សេចក្តីព្រាងប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ទំព័រ ៣)។ នៅពេលនេះ អង្គជំនុំជម្រះ ផ្តល់នូវសំអាងហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួនក្នុងការទទួលយករបាយការណ៍នេះ។

២. របាយការណ៍នេះរួមមានសេចក្តីសង្ខេបអំពីព័ត៌មានដែលមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើម-បណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236 ដែលត្រូវបានទទួលយកជាឯកសារភ័ស្តុតាងរួចហើយនៅក្នុងសំណុំរឿងនេះ និងត្រូវបានដាក់លេខឯកសារ E3/4950។ មេធាវីការពារក្តីអះអាងថា របាយការណ៍នេះមានការលើកឡើងអំពីពូររបស់ដើមបណ្តឹងរដ្ឋប្ប-វេណី 2-TCCP-236 ដែលមិនមាននៅក្នុងឯកសារ E3/4950 (ឯកសារ E419 កថាខណ្ឌ ៦)។ ដូច្នេះ មេធាវីការពារក្តីស្នើសុំប្រើប្រាស់របាយការណ៍នេះក្នុងអំឡុងពេលខ្លួនសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី2-TCCP-236។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា របាយការណ៍នេះមានលក្ខណៈគ្រប់គ្រាន់ជាចម្លើយរបស់សាក្សីពីមុន ហើយពិតជាមានភាពពាក់ព័ន្ធទៅនឹងការវាយតម្លៃអំពីភាពទុកចិត្តបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236 (ឯកសារ E419 កថាខណ្ឌ ៧)។

៣. សហមេធាវីនាំមុខអះអាងថា របាយការណ៍នេះមិនមានលក្ខណៈគ្រប់គ្រាន់ជាចម្លើយរបស់សាក្សីពីមុនឡើយ ដោយសារតែរបាយការណ៍នេះត្រូវបានអង្គភាពគាំពារជនរងគ្រោះរៀបចំឡើងសម្រាប់គោលបំណងផ្នែករដ្ឋបាលប៉ុណ្ណោះ ដោយមិនបានធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធរូបនេះឡើយ ហើយគាត់មិនបានពិនិត្យមើលឡើងវិញ និងមិនបានចុះហត្ថលេខាលើឯកសារនេះទេ (ឯកសារ E419/1 កថាខណ្ឌ ៧-១១)។ សហមេធាវីនាំមុខអះអាងថា របាយការណ៍នេះពុំមានសញ្ញាណនៃភាពជឿជាក់បាន ដែលជាលក្ខខណ្ឌកំណត់នៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងទេ ហើយរបាយការណ៍នេះមិនគួរត្រូវបានទទួលយកជាឯកសារភ័ស្តុតាងឡើយ (ឯកសារ E419/1 កថាខណ្ឌ ១១, ១៤)។

៤. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃការនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកភ័ស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមាន

ប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏បំពេញផងដែរ នូវបទដ្ឋាន*ការបញ្ជាក់បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលខ្លួនស្នើសុំដាក់ មិនអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញទោះបីជាបានយកចិត្តទុកដាក់សមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណា នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំង ក្នុងករណីដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និងករណីដែលឯកសារដែលបានស្នើសុំដាក់នេះ គឺជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E276/2 កថាខណ្ឌ ២ ដែលយោងទៅឯកសារ E190 និងឯកសារ E172/24/5/1, ឯកសារ E260 កថាខណ្ឌ ៥)។

៥. មេធាវីការពារក្ដី នួន ជា ពុំបានផ្ដល់នូវសេចក្ដីពន្យល់ឡើយថាហេតុអ្វីបានជាខ្លួនមិនបានស្នើសុំឱ្យទទួលយករបាយការណ៍នេះ ដែលចុះកាលបរិច្ឆេទថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ មុនពេលការចាប់ផ្ដើមជំនុំជម្រះ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើនេះគឺជាសំណើដែលដាក់យឺតពេល។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះនឹងពិចារណាថាតើ របាយការណ៍នេះគួរត្រូវបានទទួលយក ឬ យ៉ាងណា ទោះបីជាមេធាវីការពារក្ដី នួន ជា មិនបានយកចិត្តទុកដាក់សមស្របក៏ដោយនោះ។

៦. អង្គជំនុំជម្រះកត់សម្គាល់ទៅលើសេចក្ដីសន្និដ្ឋានរបស់សហមេធាវីនាំមុខថា របាយការណ៍នេះត្រូវបានរៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះ ដោយផ្អែកតែទៅលើឯកសារពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ ហើយមិនត្រូវបានទទួលស្គាល់ដោយដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-236 ឡើយ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា របាយការណ៍នេះមិនមានលក្ខណៈគ្រប់គ្រាន់ជាចម្លើយរបស់សាក្សីឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំ

ជម្រះយល់ឃើញថា របាយការណ៍នេះ *តាមការបញ្ជាក់បឋម* មានភាពពាក់ព័ន្ធ អាចជឿជាក់បាន និងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដទៃទៀតដែលមានរួចហើយនៅក្នុងសំណុំរឿង ជាពិសេសគឺពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236 ដែលត្រូវបានទទួលយករួចហើយជាឯកសារ E3/4950។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា របាយការណ៍ផ្សេងៗទៀតរបស់អង្គភាពគាំពារជនរងគ្រោះអំពីពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២ (សូមមើល ឧទា. ឯកសារ E3/6242, ឯកសារ E3/5840, ឯកសារ E3/4620, ឯកសារ E3/1731) ហើយថា ការប្រើប្រាស់របាយការណ៍ទាំងនេះនៅក្នុងសវនាការ អាចត្រូវបានជំទាស់ពីភាគីដទៃទៀត (សូមមើល ឧទា. ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៦៨-៦៩)។ តម្លៃជាភ័ស្តុតាងនៃរបាយការណ៍នេះ នឹងត្រូវយកមកវាយតម្លៃនៅក្នុងដំណាក់កាលព្រាងសាលក្រម ដោយពិចារណាទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធ និងភ័ស្តុតាងដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើមាន។ ទោះបីជាសំណើនេះមានភាពយឺតយ៉ាវក៏ដោយ ក៏ការទទួលយករបាយការណ៍នេះគឺជាប្រយោជន៍យុត្តិធម៌ដែរ ពីព្រោះវាជាព័ត៌មានបន្ថែមទៅនឹងពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236។ ដូច្នេះ អង្គជំនុំជម្រះយល់ស្របតាមសំណើ និងទទួលយករបាយការណ៍នេះជាឯកសារ E3/4950a។

៧. នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E419។